# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ២៩ មិនា ២០២០

## *សម្រាប់អ្នកធ្វើដំណើរ ឬមានលំនៅនៅ Revere Beach ត្រូវរក្សាគម្លាតសង្គម*
## *ហាងអាហារនានា ត្រូវប្តូរមកជាសេវាកម្មដឹកជញ្ជូន*
## *រកឃើញអ្នកឆ្លងសរុបចំនួន ៨៨ នាក់*

ថ្ងៃទី២៩ ខែមិនា ២០២០ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។

នៅថ្ងៃទី ២៩ មិនា ២០២០ នេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន ៨៣ នាក់។ ចំនួននេះបានហក់ឡើងគួរឲ្យកត់សម្គាល់នៅដើមសប្តាហ៍ បន្ទាប់ពីក្នុងក្រុងទាំងមូលរកឃើញអ្នកឆ្លងចំនួន ៨ នាក់។

ដើម្បីជាចំណែកមួយក្នុងការកាត់បន្ថយល្បឿននៃការរីករាលដាលជំងឺ នៅព្រឹកថ្ងៃអាទិត្យនេះ ក្រុមអធិការកិច្ចប្រចាំក្រុងបានចុះផ្សព្វផ្សាយដល់រាល់ហាងអាហារទាំងអស់ដែលស្ថិតនៅលើផ្លូវ Revere Beach ឲ្យបញ្ឈប់ការលក់ដូរផ្ទាល់ រហូតមានការផ្សាយដំណឹងបន្ថែម។  ក្នុងនោះ ហាងនីមួយៗអាចជ្រើសរើសវិធានការណាមួយក្នុងចំណោម ផ្តល់តែសេវាដឹកជញ្ជូនសុទ្ធ ឬបិទហាងបណ្តោះអាសន្នតែម្តង។

លោកអភិបាល Arrigo ក៏បានចុះទៅមើលស្ថានភាពលើដងផ្លូវ Revere Beach កាលពីថ្ងៃអាទិត្យនេះជាមួយរថយន្តរបស់សាលាក្រុង និងប្រើមេក្រូដើម្បីប្រកាសទាក់ទងទៅកាន់ប្រជាជន ស្របតាមការណែនាំនៃវិធីរក្សាគម្លាតសង្គម ក៏ដូចជាកាត់បន្ថយហានិភ័យនៃការឆ្លងផងដែរ។

"ខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់អាជីវកម្មហាងអាហារទាំងអស់ដែលបានសហការជាមួយពួកយើងក្នុងគ្រាដ៏លំបាកនេះ តែវាពិតជាចាំបាច់ ក្នុងការបញ្ឈប់ការលក់ដូរផ្ទាល់។ កន្លងមក យើងបានធ្វើរឿងជាច្រើន ដើម្បីឲ្យប្រជាជនស្នាក់នៅផ្ទះ និងគោរពតាមការណែនាំនៃវិធីរក្សាគម្លាតសង្គម នៅពេលដែលគេពិតជាចាំបាច់ត្រូវចេញក្រៅផ្ទះ។ យើងត្រូវការកិច្ចសហការពីសហគមន៍ទាំងមូល ដើម្បីកាត់បន្ថយល្បឿននៃការឆ្លងដ៏រហ័សនេះ"។ នេះជាសម្តីរបស់លោកអភិបាល Arrigo។

លោកអភិបាលក្រុង និងសមាជិកនៃក្រុមឆ្លើយតបរហ័សនៅតែបន្តមានកិច្ចប្រជុំរៀងរាល់ថ្ងៃ ដើម្បីសង្ខេបស្ថានការណ៍ថ្មីៗ។ មន្ត្រីនានាទីក្រុង និងក្រុមសហព័ន្ធក៏ចូលរួមក្នុងការសង្ខេបស្ថានការណ៍ប្រចាំថ្ងៃនេះ ដើម្បីសម្របសម្រួល និងរកមធ្យោបាយដោះស្រាយបញ្ហាផ្ទៃក្នុង។ ការអាប់ដេតទាំងអស់ នឹងត្រូវធ្វើជាទៀងទាត់នៅគេហទំព័រ Revere.org/coronavirus និងតាមបណ្តាញសង្គម។

# សេវាកម្មរបស់ក្រុង

**អាប់ដេត**

- លោកអភិបាលក្រុង Arrigo បានប្រកាសពីភាពអាសន្ននៃការឆ្លងនៅក្នុងក្រុង Revere កាលពីថ្ងៃ ១៩ មិន ២០២០។
- សេវាកម្មមូលដ្ឋានរបស់ទីក្រុងដែលផ្តល់ដោយប៉ូលីស Revere អគ្គីភ័យ, EMS មន្ទីរសាធារណការ និង Revere 311 នឹងបន្តផ្តល់ជូនប្រជាពលរដ្ឋ ដោយគ្មានការរំខានណាមួយឡើយ។
- អ្នករស់នៅ Revere គួរតែ Subscribe សេវាបញ្ជូនព័ត៌មានតាមអ៊ីម៉ែល និងសារជាអក្សរតាម revere.org/coronavirus ដើម្បីទទួលបានព័ត៌មានថ្មីៗ។
- Revere 311 នៅតែមានបុគ្គលិក ចាំឆ្លើយសំណួរ ឬដោះស្រាយកង្វល់ផ្សេងៗជូនប្រជាបលរដ្ឋ។ សូមទាក់ទងមកកាន់ 311 ឬ 781-286-8311 ឬអ៊ីម៉ែលមក Revere311@revere.org ។
- អាគារសាធារណៈក្នុងទីក្រុងទាំងអស់ត្រូវបានបិទ រហូតដល់មានការជូនដំណឹងបន្ថែម។ សេវាកម្មនានានៅតែផ្តល់ប្រជាជនតាមគេហទំព័រ Revere.org។
- រាល់សួនច្បារ និងសួនកុមារទាំងអស់ត្រូវបានបិទ រហូតដល់ថ្ងៃជូនដំណឹងបន្ថែម។
- សាលារដ្ឋនៅក្នុងក្រុង Revere នឹងមានចែកអាហារខ្ចប់ សម្រាប់សិស្សទាំងអស់ និងគ្រួសារ។ អាហារពេលព្រឹក និងថ្ងៃត្រង់ នឹងចែកជូនដល់កុមារដែលត្រូវការពីចន្ទ ដល់សុក្រ ពីម៉ោង ១០ ដល់ ១១ ព្រឹក និងម៉ោង ១១ ដល់១ ថ្ងៃត្រង់។
- អ្នកអាចស្វែងរកបណ្តាញផ្តល់ជំនួយទៅមកនៅលើ Revere.org ។ នៅទីនោះ អ្នកអាចរកបានជំនួយយ៉ាងទូលំទូលាយ ប្ញក្សរួមទាំងផ្នែកចំណីអាហារ សេវាថែទាំសុខភាព សេវាធ្វើដំណើរ សិទ្ធជ្រកកោន និងសេវាផ្សេងៗទៀត។ ព័ត៌មានទាក់ទងនឹងសេវាទាំងនេះ នឹងមានការអាប់ដេតជារៀងរាល់ថ្ងៃនៅម៉ោង ៤ ល្ងាច។
- ទីក្រុង Revere បានបង្កើត ទំព័រ មួយ ដែលបង្ហាញព័ត៌មានពីដំណោះស្រាយ និងជំនួយទៅដល់អ្នកដែលបានរងផលប៉ះពាល់ ដូចជាអាជីវកម្មខ្នាតតូច នយោជក អាជីវកម្មមិនយកប្រាក់ចំណេញ និងកម្មករ។ ទំព័រនេះនឹងមានការអាប់ដេតជាប្រចាំថ្ងៃ រាល់ពេលដែលអ្វីៗមានការប្រែប្រួល។
- ក្រុមស្ម័គ្រចិត្ត volunteer database នឹងបើករាល់ថ្ងៃសុក្រ សម្រាប់អ្នកដែលចង់រកកម្មី ឬជំនួយក្នុងរយៈពេលច្រើនសប្តាហ៍ខាងមុខ។ អ្នកដែលបានចុះឈ្មោះធ្វើជាអ្នកស្ម័គ្រចិត្តរួច នឹងមានក្រុមការងារទាក់ទងទៅឆាប់ៗ ក្រោយបំពេញឯកសារគ្រប់គ្រាន់។

# សកម្មភាពដែលអ្នករស់នៅក្នុងក្រុង Revere ត្រូវធ្វើ៖

នាយកដ្ឋានថែទាំសុខភាពសាធារណៈរបស់រដ្ឋ Massachusetts បានចេញសេចក្តីណែនាំឲ្យប្រជាជានទាំងអស់ "ត្រូវស្នាក់នៅផ្ទះ"។ លោកអភិបាល Baker បានធ្វើការហាមមិនឲ្យមានការជួបជុំមនុស្ស លើសពី ១០ នាក់។ ការស្នាក់នៅផ្ទះមានន័យថា ជៀសវាងការធ្វើការ ឬធ្វើសកម្មភាពណាដែមិនចាំបាច់ ក្នុងរយៈពេល ២ សប្តាហ៍ខាងមុខ។ ប្រជាជនដែលមានអាយុលើសពី ៧០ និងអ្នកមានសុខភាពទន់ខ្សោយ គួរតែកាត់បន្ថយការជួបជុំ ឬប៉ះពាល់ជាមួយមនុស្សទូទៅតាមដែលអាចធ្វើបាន។

តាមរយៈការណែនាំរបស់មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ Centers for Disease Control បានប្រាប់ពីវិធីងាយៗមួយចំនួនដើម្បីការពារខ្លួនពីវីរ៉ុសក្លូរ៉ូណារួមមាន៖ លាងដៃឲ្យបានញឹកញាប់ ជៀសវាងការនៅជិតអ្នកដែលឈឺ ត្រូវស្នាក់នៅផ្ទះពេលឈឺ ខ្ទប់មាត់ពេលក្អក និងកណ្តាស់ សម្អាតដៃ និងរំងាប់មេរោគលើរបស់ដែលអ្នកប៉ះញឹកញាប់។